សហគមន៍ខ្មែរកម្ពុជាក្រោម
KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ.................................ស.ខ.ក.ក.

# លិខិតរំលែកទុក្ខ

## ជូនលោក សឺន ត្រៀង និងគ្រួសារសព

ក្នុងនាមថ្នាក់ដឹកនាំ សមាជិក សមាជិកា សហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់មានសេចក្ដីតក់ស្លុតរន្ធត់ចិត្តយ៉ាងខ្លាំង នៅពេលដែលបានទទួលដំណឹងអកុសលថា លោកឧត្តមព្រឹទ្ធាចារ្យ សឺន តូ ហៅ លោកគ្រូ ឱន បានទទួលអនិច្ចកម្មនៅមន្ទីរពេទ្យ St. Talon ទីក្រុង Montréal វេលាម៉ោង៩និង៣០នាទី យប់ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១៣ ក្នុងជន្មាយុ៩១ឆ្នាំ ដោយជរាពាធ។

មរណភាពរបស់លោកឧត្តមព្រឹទ្ធាចារ្យ សឺន តូ គឺជាការបាត់បង់លោកឪពុក បាត់បង់ជីតា ជីតាទួតដ៏ជាទីគោរព និងជាទីស្រឡាញ់ និងជាការបាត់បង់បញ្ញវន្តខ្មែរដែលជាវីរជនស្នេហាជាតិ និងស្នេហាព្រះ-ពុទ្ធសាសនាមួយរូបដ៏សំខាន់។

លោកឧត្តមព្រឹទ្ធាចារ្យ សឺន តូ គឺជាវីរជនស្នេហាជាតិមួយរូបដ៏បរិសុទ្ធ ដែលស្ទើរពេញក្នុងមួយជីវិតរបស់លោកបានលះបង់ដើម្បីជាតិ និងសាសនាដោយគ្មានរួញរាឡើយ មិនថារស់នៅទីណា ជីវភាពលំបាកបែបណាទេ។ ទោះបីលោកឧត្តមព្រឹទ្ធាចារ្យ ត្រូវបានអាជ្ញាធរអាណានិគមយួនចាប់ដាក់ពន្ធនាគារ និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃក៏ដោយ ទោះលោកបានរត់គេចខ្លួនពីក្រញាំបីសាចយួន ទៅរស់នៅប្រទេសកាណាដាក្ដី មានវ័យចាស់ជរាក្ដី លោកឧត្តមព្រឹទ្ធាចារ្យ លោកមិនដែលបោះបង់ឧត្តមគតិស្នេហាជាតិម្ដងណាឡើយ គឺលោកនៅតែរក្សាយ៉ាងខ្ជាប់ខ្ជួននូវទំនៀមទម្លាប់វប្បធម៌ដ៏ល្អផូរផង់របស់ខ្មែរជានិច្ច។ មិនតែប៉ុណ្ណោះលោកបានខិតខំស្រាវជ្រាវតែងនិពន្ធសៀវភៅមួយចំនួនទុកសម្រាប់កូនខ្មែរជំនាន់ក្រោយទៀតផង។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុត ជាមួយក្រុមគ្រួសារនៃសពទាំងមូល ដោយសេចក្ដីសោកស្ដាយ អាឡោះអាល័យយ៉ាងក្រៃលែង។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមវាយតម្លៃយ៉ាងខ្ពស់ ចំពោះវីរភាពស្នេហាជាតិដ៏បរិសុទ្ធរបស់លោក ឧត្តមព្រឹទ្ធាចារ្យ និងចាត់ទុកជាវីរជនគំរូសម្រាប់សហគមន៍ខ្មែរកម្ពុជាក្រោម។

ដោយអំពើល្អនៃឧត្តមគតិស្នេហាជាតិ សហគមន៍ខ្មែរកម្ពុជាក្រោម សូមធ្វើអធិដ្ឋានចំពោះ វិញ្ញាណក្ខន្ធលោកឧត្តមព្រឹទ្ធាចារ្យ សឺន តូ បានទៅសោយសុខក្នុងសុគតិភពកុំបីខាន និងសូមប្រគេនពរ និងជូនពរព្រះករុណាគ្រប់ព្រះអង្គ ក្រុមគ្រួសារសព និងពុទ្ធបរិស័ទទាំងអស់ បានប្រកបទៅដោយពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមលោក សឺន ត្រៀង និងក្រុមគ្រួសារនៃសពទាំងអស់ ទទួលនូវការចូលរួមរំលែកនូវមរណទុក្ខដោយស្មោះអស់ពីដួងចិត្ត ពីយើងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១៣
នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា
សមាជិកព្រឹទ្ធសភា

Website: www.khmerkromngo.org
Temporary Headquarters: House # 10B, Street 234, Tuk Laak commune, Tuol Kork district, Phnom Penh
Kingdom of Cambodia
Telephones: 012 908 882, 090 477 007; E-mails: thachsetha@gmail.com or kkcpressoffice@yahoo.com